# ការឆ្លងរាលដាលជាសកលនៃគ្រុនផ្តាសាយ

## តើការឆ្លងរាលដាលជាសកលជាអ្វី ?

ការឆ្លងរាលដាលជាសកល គឺជាការផ្ទុះជម្ងឺពេញពិភពលោក ។ ការឆ្លងរាលដាលជាសកលនៃជម្ងឺគ្រុនផ្តាសាយបក្សី អាចចាប់ផ្តើមឡើងនៅពេលមានលក្ខខណ្ឌបីខាងក្រោមនេះៈ

1. មានអនុប្រភេទមេរោគគ្រុនផ្តាសាយ A ថ្មីកើតឡើង ដោយមានភាពស៊ាំតែបន្តិចបន្តួច ឬគ្មានសោះនៅក្នុងចំណោមប្រជាជន ។
2. មេរោគនេះឆ្លងមកមនុស្ស បង្កអោយមានជម្ងឺធ្ងន់ធ្ងរ
3. វាឆ្លងយ៉ាងងាយ និងជាប់ជានិច្ចក្នុងចំណោមមនុស្ស

តាមប្រវត្តិសាស្ត្រ នៅសតវត្សន៍ទី20 មានការឆ្លងរាលដាលជាសកលនៃជម្ងឺគ្រុនផ្តាសាយបីដងៈ

- ឆ្នាំ 1918 ការឆ្លងរាលដាលជាសកលនៃជម្ងឺគ្រុនផ្តាសាយបណ្តាលអោយមនុស្សស្លាប់រហូតដល់ទៅ 40លាននាក់ នៅទូទាំងពិភពលោក
- ឆ្នាំ 1957 ការឆ្លងរាលដាលជាសកលនៃជម្ងឺគ្រុនផ្តាសាយបណ្តាលអោយមនុស្សស្លាប់ 1-2លាននាក់ នៅទូទាំងពិភពលោក
- ឆ្នាំ 1968 ការឆ្លងរាលដាលជាសកលនៃជម្ងឺគ្រុនផ្តាសាយបណ្តាលអោយមនុស្សស្លាប់ ប្រហែលជា 700.000នាក់ នៅទូទាំងពិភពលោក

## ហេតុអ្វីបានត្រូវបារម្ភអំពីមេរោគប្រភេទ H5N1 ?

មេរោគប្រភេទ H5N1 បានបំពេញលក្ខខណ្ឌពីរដំបូងខាងលើនេះរួចស្រេចទៅហើយ ពោលគឺៈ

1. វាជាមេរោគថ្មីសំរាប់មនុស្សជាតិ ។ មេរោគប្រភេទ H5N1 ពុំធ្លាប់ឆ្លងរាលដាលនៅក្នុងចំណោមមនុស្សទេ ដូច្នេះគ្មាននរណាម្នាក់មានភាពស៊ាំដើម្បីការពារខ្លួនទេ ប្រសិនបើមានការឆ្លងរាលដាលនៃមេរោគប្រភេទដូចជា H5N1 កើតមានឡើង ។
2. មេរោគនេះបានឆ្លងទៅមនុស្សជាង 100នាក់ ដែលជាងពាក់កណ្តាលបានស្លាប់ ។

ប្រសិនបើមេរោគប្រភេទ H5N1 មានសមត្ថភាពអាចចម្លងយ៉ាងងាយ និងជាប់ជានិច្ចក្នុងចំណោមមនុស្សនោះ យើងមុខជាប្រឈមមុខនឹង ការចាប់ផ្តើមនៃការឆ្លងរាលដាលជាសកលជាពុំខាន ។ ហានិភ័យគឺថា មេរោគប្រភេទ H5N1 មានសមត្ថភាពអាចបន្តរហូតដល់មានឱកាសអាចឆ្លងពីមនុស្សទៅមនុស្សបាន ។ ជាថ្នូរមកវិញ ឱកាសឆ្លងនេះនឹងនៅបន្តរហូតដល់មេរោគនេះ បន្តឆ្លងរាលដាលក្នុងចំណោមបក្សី ហើយស្ថានភាពនេះចេះតែបន្តរាប់ឆ្នាំទៅមុខទៀត ។

មានហេតុផលមួយចំនួនទៀតដែលនាំអោយមានការបារម្ភអំពីលទ្ធភាពដែលមេរោគប្រភេទ H5N1 អាចបង្កអោយមានការឆ្លងរាលដាលជាសកលបាន ។

1. បច្ចុប្បន្ននេះ ទាចិញ្ចឹមអាចបញ្ចេញលាមកជាបរិមាណយ៉ាងច្រើន មានមេរោគបង្កជំងឺកំរិតខ្ពស់ ដោយពុំមានបង្ហាញរោគសញ្ញាអ្វីឡើយ ហើយបច្ចុប្បន្ននេះកំពុងតែបំពេញមុខងារជាអាងស្តុកមេរោគយ៉ាង "ស្ងៀមស្ងាត់" បង្កអោយមានការចម្លងមេរោគជាប់ជាប្រចាំ ដល់សត្វស្លាបដទៃទៀត ។ ការណ៍នេះរឹតតែបន្ថែមភាពស្មុគស្មាញមួយកំរិតទៀតដល់កិច្ចប្រឹងប្រែងគ្រប់គ្រងជម្ងឺនេះ ហើយដកសញ្ញាព្រមានចំពោះមនុស្សជាតិក្នុងការចៀសវាងទង្វើប្រកបដោយគ្រោះថ្នាក់ ។
2. បើប្រៀបធៀបជាមួយមេរោគប្រភេទ H5N1 ពីឆ្នាំ1997 និងដើមឆ្នាំ2004 មេរោគប្រភេទ H5N1 ដែលកំពុងឆ្លងរាលដាលនាពេល បច្ចុប្បន្ននេះបង្កអោយមានគ្រោះថ្នាក់ដល់ជីវិតសត្វកណ្តុរ និងសត្វសំពោចដែលគេយកមកធ្វើពិសោធន៍ (គំរូថនិកសត្វ) ខ្លាំងជាងមុនទៅទៀត ហើយអាចរស់បានយូរជាងមុននៅក្នុងបរិយាកាស ។
3. មេរោគប្រភេទ H5N1 ហាក់ដូចជាបានពង្រីកវិសាលភាពជនរងគ្រោះរបស់ខ្លួន ដោយឆ្លង និងសម្លាប់ប្រភេទថនិកសត្វ ដែលដើមឡើយ គេគិតថាអាចធន់នឹងការឆ្លងមេរោគគ្រុនផ្តាសាយបក្សីបាននោះ ។

## លក្ខណៈ និងបញ្ហាប្រឈមនៃការឆ្លងរាលដាលជាសកល

1. ការឆ្លងយ៉ាងឆាប់រហ័សទូទាំងពិភពលោក
   - នៅពេលការឆ្លងរាលដាលជាសកលនៃជម្ងឺគ្រុនផ្តាសាយកើតមានឡើងហើយ ការឆ្លងទូទាំងពិភពលោកមុខជាមិនអាចចៀងវាងបានឡើយ ។
   - សកម្មភាពត្រៀមបង្ការត្រូវតែគិតថា ប្រជាជនក្នុងពិភពលោកទាំងមូល ងាយទទួលរងជម្ងឺនេះណាស់ ។
   - តាមរយៈវិធានការដូចជាការ បិទព្រំដែន ការដាក់កំហិតនៃការធ្វើដំណើរ ប្រទេសនានាអាចពន្យាពេលការមកដល់នៃមេរោគនេះ ប៉ុន្តែមិនអាចបញ្ឈប់បានទេ ។
   - ការឆ្លងរាលដាលជាសកលពីអតីតកាល បានកើតឡើងជួនៗពីរ ឬបីដង ។
2. ប្រព័ន្ធថែទាំសុខភាពមានបន្ទុកធ្ងន់ពេក
   - មនុស្សភាគច្រើនមានភាពស៊ាំ បន្តិចបន្តួច ឬ គ្មានទាល់តែសោះ ដើម្បីការពារទល់នឹងមេរោគដែលអាចឆ្លងរាលដាលជាសកលនេះ ។ អត្រាឆ្លងនិងអត្រាឈឺ កាន់តែឡើងខ្ពស់ ។ ភាគរយយ៉ាងធំនៃប្រជាជនក្នុងពិភពលោកត្រូវការកិច្ចថែទាំសុខភាព តាមរូបភាពណាមួយ ។
   - ប្រជាជាតិនានា មិនអាចមានបុគ្គលិក ឧបករណ៍ បរិក្ខារ និងគ្រែមន្ទីរពេទ្យ សំរាប់ទទួលមនុស្សក្នុងចំនួនដ៏ច្រើនដែលធ្លាក់ខ្លួនឈឺភ្លាមៗបាន ឡើយ ។

- អត្រាមរណៈភាពមានកំរិតខ្ពស់ មួយផ្នែកធំដោយសារ កត្តាបួនយ៉ាងៈ ចំនួនមនុស្សដែលឆ្លងជម្ងឺ ភាពងាយរាលដាលខ្លាំងនៃ មេរោគ លក្ខណៈជាមូលដ្ឋាន និងភាពងាយរងគ្រោះថ្នាក់នៃប្រជាជនដែលបានឆ្លងជម្ងឺ និងប្រសិទ្ធភាពនៃវិធានការបង្ការ ។

3. ការផ្គត់ផ្គង់ផ្នែក វេជ្ជសាស្រ្តមិនគ្រប់គ្រាន់
   - តំរូវការចំពោះថ្នាំបង្ការអាចលើសពីការផ្គត់ផ្គង់
   - តំរូវការថ្នាំប្រឆាំងមេរោគ ក៏អាចនឹងខ្វះខាតនៅដំណាក់កាលដំបូងនៃការឆ្លងរាលដាលជាសកល។
   - ការឆ្លងរាលដាលជាសកលអាចធ្វើអោយខ្វះខាតគ្រែមន្ទីរពេទ្យ ឧបករណ៍សំរួលខ្យល់ចេញចូល និងសម្ភារៈផ្គត់ផ្គង់ផ្សេងៗ ទៀត ។ ការបង្កើនសមត្ថភាពជាបន្ទាន់នៅតាមកន្លែងដែលមិនទាក់ទងនឹងប្រពៃណី ដូចជាសាលារៀនជាដើម ត្រូវបានបង្កើតឡើងដើម្បីដោះស្រាយតំរូវការ ។
   - ការសំរេចចិត្តដ៏លំបាកអាចនឹងត្រូវធ្វើឡើង ទាក់ទងនឹងអ្នកដែលត្រូវទទួលថ្នាំប្រឆាំងមេរោគ និងថ្នាំបង្ការ ។
4. ការរំខានផ្នែកសេដ្ឋកិច្ច និងសង្គម
   - ការហាមឃាត់ការធ្វើដំណើរ ការបិទទ្វារសាលារៀន អាជីវកម្ម និងការលុបចោលព្រឹត្តិការណ៍ផ្សេងៗ ដែលមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើសហគមន៍ និងប្រជាពលរដ្ឋ ។
   - ការថៃទាំសមាជិកគ្រួសារដែលមានជម្ងឺ និងការភ័យខ្លាចចំពោះការប្រឈមនឹងមេរោគ អាចបង្កអោយមានអវត្តមានពីការងារយ៉ាងច្រើន ។

## ការប្រាស្រ័យទាក់ទង និងការចែករំលែកពត៌មាន គឺជាផ្នែកដ៏សំខាន់នៃ ការឆ្លើយតបនឹងការឆ្លងរាលដាលជាសកល

ការអប់រំ និងការចុះទៅពន្យល់ដល់មូលដ្ឋាន មានសារៈសំខាន់ណាស់ចំពោះ ការត្រៀមលក្ខណៈទប់ទល់នឹងការឆ្លងរាលដាលជាសកល ។ ការយល់ដឹងអំពីការឆ្លងរាលដាលជាសកល អ្វីដែលត្រូវធ្វើឡើងនៅ គ្រប់លំដាប់ថ្នាក់ ដើម្បីត្រៀមលក្ខណៈចំពោះ ជំងឺគ្រុនផ្តាសាយដែលឆ្លងជាសាកលនិងអ្វីដែលអាចកើតឡើងនៅ អំឡុងពេលឆ្លងរាលដាលជាសកល ជួយអោយយើងអាចធ្វើការ សំរេចចិត្តបានល្អិតល្អន់ ជាលក្ខណៈបុគ្គល និងជាលក្ខណៈជាតិ ។ ប្រសិនបើការឆ្លងរាលដាល ជាសកល កើតមានឡើង សាធារណជនត្រូវតែអាចពឹងផ្អែកលើរដ្ឋាភិបាលរបស់ខ្លួន ក្នុងការផ្តល់ពត៌មានទាក់ទងនឹងសុខភាពដែលត្រឹមត្រូវ និងឆាប់រហ័ស បើកចំហរ និងអាចជឿទុកចិត្តបាន ។

*–ធ្វើបច្ចុប្បន្នភាពនៅ ថ្ងៃទី30 ខែធ្នូ ឆ្នាំ2005*